មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# ជីវប្រវត្តិ កញ្ញា កែវ ចាន់រិទ្ធ

## អ្នកការពារសិទ្ធិមនុស្សស្ត្រី


*"ខ្ញុំមិនដឹងថាឆ្នាំណាស្ថានភាពសិទ្ធិមនុស្សនឹងបានប្រសើជាងមុននោះទេ"*

កញ្ញា កែវ ចាន់រិទ្ធ កើតនៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៨៦ នៅភូមិស្ថានីយ៍ ឃុំស្វាយអាត់ ស្រុកសំពៅមាស ខេត្តពោធិសាត់។ កញ្ញាជាកូនច្បង ក្នុងគ្រួសារដែលមានបងប្អូន ៧ នាក់។ ឪពុកម្តាយ ចាន់រិទ្ធគឺជាអាជីវករនៅស្រុកសំពៅមាស។ ដោយសារនៅស្រុកសំពៅមាសមិនមានសាលារៀនគ្រប់គ្រាន់ ចាន់រិទ្ធ បានមករស់នៅជាមួយតា យាយ នៅទីរួមខេត្តពោធិសាត់តាំងពីកុមារភាព រហូតរៀនចប់វិទ្យាល័យពោធិសាត់ក្នុងឆ្នាំ២០០៦។ នៅឆ្នាំ២០០៧ កញ្ញាចាន់រិទ្ធ បានបន្តការសិក្សារបស់ខ្លួន នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅរាជធានីភ្នំពេញ ដោយជ្រើសរើសយកមុខជំនាញសេដ្ឋកិច្ច ហើយបានបញ្ចប់ថ្នាក់បរិញ្ញាបត្រនៅឆ្នាំ២០១១។

ដោយមើលឃើញបញ្ហារំលោភសិទ្ធិមនុស្ស និងភាពអយុត្តិធម៌សង្គមតែងតែកើតមាននៅប្រទេសកម្ពុជា ជាពិសេសការរំលោភបំពានពីសំណាក់អ្នកមានមកលើអ្នកក្រ បានជម្រុញឲ្យកញ្ញាចង់ធ្វើការក្នុងអង្គការសង្គមស៊ីវិលយ៉ាងខ្លាំងដើម្បីលើកកម្ពស់ការយល់ដឹងផ្នែកសិទ្ធិមនុស្ស។ ម្លោះហើយនៅពេលកំពុងសិក្សានៅមហាវិទ្យាល័យ ក្នុងឆ្នាំ២០០៩ កញ្ញា ចាន់រិទ្ធ បានស្ម័គ្រចិត្តធ្វើការក្រៅម៉ោងនៅអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនដូចជា ក្រុមប្រឹក្សាយុវជនកម្ពុជា និងអង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន។ នៅឆ្នាំ២០១០ កញ្ញាបានដាក់ពាក្យធ្វើការនៅសមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA) ហើយត្រូវបានជ្រើសរើសជាមន្ត្រីផ្នែកចងក្រង។ នៅឆ្នាំ២០១៤ កញ្ញា ចាន់រិទ្ធ បានជាប់ជាអគ្គលេខាធិការរងទទួលបន្ទុកផ្នែកអាជីវកររបស់សមាគម។

នៅសមាគម IDEA កញ្ញា ចាន់រិទ្ធ ត្រូវចុះទៅចងក្រងអ្នកដែលប្រកបមុខរបរសេដ្ឋកិច្ចក្រៅប្រព័ន្ធ រៀបចំអង្គប្រជុំ ធ្វើរបាយការណ៍ រៀបចំផែនការ ព្រមទាំងបណ្តុះបណ្តាលសមាជិកសមាគមឲ្យយល់ដឹងពីសិទ្ធិរបស់ពួកគាត់ និងចេះសាមគ្គីគ្នា។ ក្រៅពីនេះកញ្ញាត្រូវចេញមុខដោះស្រាយវិវាទរបស់អាជីវករដែលជាសមាជិកផងដែរ។

ហូតមកដល់ពេលនេះសមាគម IDEA បានចងក្រងអាជីវករនៅខេត្តក្រុងចំនួនបីគឺ រាជធានីភ្នំពេញ ខេត្តបាត់ដំបង និងខេត្តកំពត ដែលមានអាជីវករសរុបប្រមាណ ៦០០នាក់។

ការចងក្រងអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធមិនមែនងាយស្រួលនោះទេ។ អាជីវករដែលមានតូបធំៗ ឬអាជីវករដែលមានតូវលក់ដូរត្រឹមត្រូវគាត់មិនចាប់អារម្មណ៍នឹងការចូលជាសមាជិកសមាគមនោះទេ។ រីឯសមាជិករបស់សមាគមភាគច្រើនសុទ្ធសឹងតែជាអាជីវករក្រីក្រ ឬអ្នកដែលងាយរងគ្រោះដូចជាអ្នកលក់ដូរចល័តនៅតាមដងផ្លូវ អ្នកលក់ដូរនៅតាមដងផ្លូវ អាជីវករក្នុងផ្សារលក់ដូរក្រោមធ័ត្រជាដើម ហើយពួកគេទាំងនោះតែងរងការបង្ខំឲ្យចល័តពីកន្លែងមួយទៅកន្លែងមួយ ហើយមានការភ័យខ្លាចមិនហានតវ៉ាជាមួយសន្តិសុខផ្សារ ឬប្រធានផ្សារនោះទេ។

ជាក់ស្តែង មុនបុណ្យចូលឆ្នាំខ្មែរក្នុងឆ្នាំ២០០៥ អាជីវករម្នាក់ក្នុងផ្សារដើមគរត្រូវប្រធានផ្សារហាមមិនឲ្យអាយលក់ដូរនៅពេលគាត់ប្តូរពីលក់សាច់ជ្រូក មកលក់ត្រីវិញ។ ជំនួសមកវិញប្រធានផ្សារនោះបញ្ជាឲ្យអាជីវករប្តូរមកបន្លែវិញ។ ដោយសារអាជីវករមិនយល់ព្រម ប្រធានផ្សារបានបង្គាប់ឲ្យសន្តិសុខរឹបអូសយកគ្រែរបស់គាត់ដែលដាក់លក់នៅក្រោមធ័ត្រ។ អាជីវករដែលដែលមានវិវាទនោះបានសុំឲ្យសមាគមជួយអន្តរាគមករណីនេះ។ កញ្ញា ចាន់ រិទ្ធ បានចេញមុខដោះស្រាយបញ្ហាជូនអាជីវករ ប៉ុន្តែនៅពេលទៅជួបមន្ត្រីផ្សារ គេរុញឲ្យទៅជួបអ្នកនេះ ទៅជួបអ្នកនោះចុះឡើងៗ ដែលជាអ្នកមិនមានសិទ្ធិសម្រេចក្នុងការដោះស្រាយ *"នៅពេលយើងទៅរកយុត្តិធម៌យើងមិនដឹងថាទៅរកនៅទីណា គឺយើងប្រមូលផ្តុំគ្នាបានមែនតែគេរិលយើងដូចកន្ទេះឡង់អីចឹង"*។ ប៉ុន្តែក្នុងនាមជាមន្ត្រីដោះស្រាយវិវាទកញ្ញាត្រូវបត់បែនតាមកាលៈទេសៈ បើមិនដូច្នេះទេទំនាស់នឹងបញ្ចប់ដោយគ្មានដំណោះស្រាយ ហើយករណីស្រដៀងគ្នានេះកញ្ញាចាន់រិទ្ធតែងតែជួបប្រទះជារឿយៗ។

ក្រៅពីធ្វើការលើវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ កញ្ញាកត់សម្គាល់ឃើញថា សេរីភាពមូលដ្ឋាននៅប្រទេសកម្ពុជានៅមានកម្រិតនៅឡើយ។ ទោះបីជាសេរីភាពទាំងនោះមានចែងនៅក្នុងច្បាប់ហើយក៏ដោយ តែការអនុវត្តមិនស្របតាមច្បាប់នោះទេ។ ឯការរំលោភបំពានសិទ្ធិមនុស្ស និងភាពអយុត្តិធម៌នៅក្នុងសង្គមនៅកើតមានឥតឈប់ឈរ។ ទាំងនេះគឺជាអ្វីដែលរដ្ឋត្រូវទទួលខុសត្រូវ។ ក្រៅពីរដ្ឋ ក្នុងនាមជាប្រជាពលរដ្ឋយើងត្រូវចូលរួមទាមទារឲ្យមានការគោរពសិទ្ធិដោយខ្លួនឯងផងដែរ។

ទោះបីជាយ៉ាងណាក៏ដោយកញ្ញាចាន់រិទ្ធមិនមានជំនឿលើរដ្ឋាភិបាលកម្ពុជាក្នុងការដោះស្រាយទៅលើការរំលោភបំពានសិទ្ធិមនុស្សដែលកំពុងបន្តកើតឡើងនោះទេ ផ្ទុយទៅវិញកញ្ញាកត់សម្គាល់ឃើញថាស្ថានភាពសិទ្ធិមនុស្សនៅប្រទេសកម្ពុជាកាន់តែដុនដាបទៅ ហើយមន្ត្រីអនុវត្តច្បាប់នៅមានភាពមិនច្បាស់លាស់ *"ខ្ញុំមិនដឹងថាឆ្នាំណាស្ថានភាពសិទ្ធិមនុស្សនឹងបានប្រសើរជាងមុននោះទេ។ តាំងពីខ្ញុំចូលធ្វើការនៅឆ្នាំ២០១០ រហូតដល់ឆ្នាំ២០១៥ ស្ថានភាពកាន់តែតឹងតែងទៅៗ ការរំលោភនៅតែរំលោភ"*។

ចប់